# កុំអាល...អី!

(បទពាក្យ៩)

ផ្កាល្អស្រស់ សម្ផស្សឆើត អើតញញឹម<br>
ភ័ក្ត្រប៉ប្រិម ឆោមប៉ប្រិយ គាប់នេត្រា<br>
កាយល្វត់ល្វន់ ទន់ល្មត់ល្វៃ សមចិន្តា<br>
ទាញឱរា អោយប្រាថ្នា មកថ្នមបី។

គួរអោយស្ដាយ កាយទ្រលុក សាច់ទ្រលន់<br>
បានត្រឹមគន់ ភ័ក្ត្រស្រទន់ នេត្រមានន័យ<br>
នឹងចរចា សុំស្នេហ៍ស្នង ពីស្រស់ស្រី<br>
នឹកឃើញវ័យ មិនអាចលៃ ល្បែងស្នេហា។

ពុកម៉ែផ្ដាំ កូនចងចាំ គ្រប់នាទី<br>
អោយសំភី ទាំងយប់ថ្ងៃ ប្រឹងសិក្សា<br>
កុំជ្រមក់ ងក់ជ្រមុជ ជុចស្នេហា<br>
នាំចិន្តា បែកសាខា បែរវាយមាយ។

ធ្វើដំណើរ តាមដងផ្លូវ នៅពេលព្រឹក<br>
ខ្យល់រអឹក ផាត់ក្លែបក្លិន ក្រអូបភាយ<br>
ចោលនេត្រា គន់បុប្ផ វីកស្គុះស្គាយ<br>
ខំស្វាធ្យាយ បណ្ដាំពុក ទុកក្នុងចិត្ត។

បើបណ្ដោយ អោយចិន្តា ភ្លឹកភ្លើតភ្លើន<br>
ចិត្តព្រហើន នឹងដឹកនាំ ពាំជីវិត<br>
អោយទៅកាន់ ឋានហ្មងសៅ ខ្មៅងងឹត<br>
គ្រានោះពិត គិតវិលវល់ ឥតកោះត្រើយ។

ខ្ញុំជាមនុស្ស រស់លើលោក នឹងគេដែរ<br>
បេះដូងស្នេហ៍ ខ្ញុំមានពិត ឥតកន្តើយ<br>
តែពេលនេះ វ័យសិក្សា មិនហ៊ានឡើយ<br>
កាមទេពអើយ កុំអាលបាញ់ ផ្ញាញ់ចិន្តា។

អ្នកកុំប្រឹង កាប់ប្រល័យ អោយប្រលាក់<br>
ចងគួចឆ្វាក់ ផ្ទាក់កាមគុណ ទុនកាមា

ខ្ញុំបារម្ភ ក្រែងប៉ះចំ ទុក្ខខ្លោចផ្សា
នាំវាសនា អស់ខ្លឹមសារ អាប់រស្មី។
ណ្ហើយ!ដួងចិត្ត បិទបេះដូង ឈប់ប្រាថ្នា
ល្បែងស្នេហា លើកទុកសិន កុំអាលអី
បើអ្នកចង់ បេះបុប្ផ មកថ្នមបី
ឆាប់ឃ្លាតខ្ញី លៃរូសរាន់ រកវិជ្ជា។
កើតជាមនុស្ស លើលោកិយ បើល្ងិតល្ងង់
ប្រៀបដូចលង់ វង់វិលវល់ ក្នុងអធ្វា
ដូចសំពៅ ត្រូវដាច់ក្តោង ក្នុងជលធារ
ច្បាស់វេរា វងវងា ឥតទិសដៅ។
អ្នកគួរចេះ ត្រិះរិះគិត គ្រប់នាទី
លើកជីវី ស្ទួយជីវិត ផុតហ្មងសៅ
ទោះអួរអាប់ យ៉ាប់ម្តេចម្តា ស៊ូទ្រាំទៅ
កុំរស់នៅ ចាំបន្ទោស ព្រហ្មលិខិត។
ប៉ងបុប្ផ ចាំមានការ មានចំណេះ
គង់អាចបេះ ផ្កាមកថ្នម សមដួងចិត្ត
ផ្កាជាប់មែក មិនប្រកែក ថៃមអាណិត
ប្រគល់ចិត្ត ជូនជីវិត អោយថ្នមថៃ។
ហ្នឹងទើបជា ពេលវេលា ដែលត្រូវគិត
បែងកំរិត យកដួងចិត្ត បូជាស្នេហ៍
បេះផ្កាហើយ ខំថ្នមថ្នាក់ កុំប្រួលប្រែ
ជួយគ្នាថៃ ស្នេហ៍ស្មោះស្ម័គ្រ ផុតសាមាន្យ។
យកវិជ្ជា ជាប្រទីប បំភ្លឺផ្លូវ
ដើរអោយត្រូវ ដៅអោយត្រង់ កុំស្ទានៗ
ពឹងចំណេះ ចេះជំនាញ ជាមូលដ្ឋាន
ស្ទួយគ្រួសារ អោយសុខសាន្ត ថ្កើងថ្កានអើយ។✍

*(០៩ មីនា ២០០១)*

*ភិក្ខុ ស្វាត សាលឿម*